# ស្ត្រី

# ដណឌណ

# ២០០៦

# ព្រះរាជក្រម

នស/រកម/០៥០៦/០១១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជនាក្សត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃ លើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម ។

រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៣.-**

ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផល ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសជលផលដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ

ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថានដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា ៤.-**

ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ឬធំតុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម ។

**មាត្រា ៥.-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## រដ្ឋបាលជលផល

**មាត្រា ៦.-**

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផលស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ﾅ

**មាត្រា ៧.-**

អនុលោមតាមគោលការណ៍តម្លាភាពដោយធានានូវសិទ្ធិសាធារណៈ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រង ការប្រើប្រាស់ ការអភិរក្ស និងអភិវឌ្ឍន៍ផលផលប្រកបដោយនិរន្តរភាព រដ្ឋបាលជលផលមានមុខងារសំខាន់ៗដូចតទៅ :

-ការងាររដ្ឋបាលរួមមាន ការគ្រប់គ្រងរដ្ឋបាល ការចាត់ចែងរាល់សកម្មភាពជលផល និងអភិវឌ្ឍន៍សហគមន៍នេសាទ

-ការងារបច្ចេកទេសរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ អភិរក្ស អភិវឌ្ឍន៍សេដ្ឋកិច្ច បច្ចេកវិទ្យាជលផល និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងជលផល ព្រមទាំងការបង្កើនវារីវប្បកម្ម

-ការងារអនុវត្តច្បាប់រួមមាន ការងារអធិការកិច្ច ការអង្កេត ការតាមដាន និងការត្រួតពិនិត្យរាល់សកម្មភាពជលផលក្នុងតួនាទីជានគរបាលយុត្តិធម៌ ។

## ជំពូកទី ៣
## ដែននេសាទ

**មាត្រា ៨.-**

ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល ។

ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ ។

ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្តៅ វាលភក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវជំនោរ និងនាទីព្រៃលិចទឹក ។

ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង ។

**មាត្រា ៩.-**

ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ព្រំប្រទល់នៃដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

រាល់ការប្រើប្រាស់ដែននេសាទដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ដែននេសាទអាចគ្របដណ្តប់លើដីសាធារណៈ ឬ ដីកម្មសិទ្ធិឯកជននារដូវជំនន់ ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ដែននេសាទទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដើម្បីធ្វើអាជីវកម្មនេសាទ ប្រមូលផលធនធានជលផល ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬ តម្រូវការចាំបាច់ផ្សេងៗទៀត ។

**មាត្រា ១០.-**

ដែននេសាទទឹកសាប គឺជាផ្ទៃទឹកដែលលាតសន្ធឹងចាប់ពីដែននេសាទសមុទ្ររហូតដល់ព្រំប្រទល់ដីគោកនៃព្រះរាជាណាចក្រកម្ពុជា ។

ដែននេសាទទឹកសាបចែកជា :

- ឡូតិ៍នេសាទដែលទុកសម្រាប់សម្បទានដល់ការវិនិយោគ ឬ ផ្តល់ឱ្យធ្វើអាជីវកម្មនេសាទ
- កន្លែងអភិរក្សជលផលដែលជាជម្រករក្សាពូជវារីសត្វ និងរុក្ខជាតិ
- ទឹកទីព្រៃលិចទឹករួមមាន តំបន់ព្រៃលិចទឹកដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណី ឬ កន្លែងពងកូន និងតំបន់លិចទឹកដែលត្រូវការពារ
- កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ
- កន្លែងនេសាទបម្រុង ជាកន្លែងនេសាទទាំងឡាយដែលពុំបានធ្វើការចាត់ថ្នាក់
- កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម
- ទំនាបលិចទឹកក្នុងរដូវជំនន់ ។